**Declassified to Public**
**06 September 2012**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
Nation Religion Roi

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 24 / 01 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 001/18-07-2007-ECCC-OCIJ**

# កំណត់ហេតុនៃការសួរចម្លើយ
# Written Record of Interview of Charged Person
# Procès-verbal d'interrogatoire

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 01 / 2008
ម៉ោង (Time/Heure): 15 : 10 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឆ្នាំពីរពាន់ប្រាំបី ខែមករា ថ្ងៃទីម្ភៃមួយ នៅវេលាម៉ោងប្រាំបួននិងដប់នាទី
យើង **យូ ប៊ុនឡេង** និង Marcel Lemonde ជាសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ
ដោយមានលោក ហាម ហ៊ើល និង លោក លី ច័ន្ទតុលា ជាក្រឡាបញ្ជីអមផង
បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤
បានឃើញវិធាន ៥៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ
ដោយមានវត្តមានរបស់ អ៊ុច ចាន់ណូរ៉ា និង តាន់ប៉ាង ដាវ័ណ្ណ ជាអ្នកបកប្រែនៃអង្គជំនុំជម្រះវិសាមញ្ញដែលបានស្បថរួចហើយ។

ជនត្រូវចោទដែលមានអត្តសញ្ញាណដូចខាងក្រោម បានចូលខ្លួននៅចំពោះមុខយើង:
ឈ្មោះ**កាំង ហ្គេកអ៊ាវ** ហៅ ឌុច ភេទ ប្រុស កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២។
ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពី **បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង **ការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ សីហា ឆ្នាំ ១៩៤៩**



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

បទល្មើសដែលមានចែង និង ផ្តន្ទាទោស តាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

ច្បាប់ដើមនៃកំណត់ហេតុនេះ ត្រូវបានសរសេរជាភាសាខ្មែរ។

សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ លោក Robert Petit និង អ្នកស្រី ជា លាង ដែលត្រូវបានជូនដំណឹងត្រឹមត្រូវរួចហើយអំពីការសួរចម្លើយនេះ នៅក្នុងលិខិតជូនដំណឹង ចុះថ្ងៃទី ៩ ខែមករា ឆ្នាំ២០០៨ ៖

☒ អ្នកស្រី ជា លាង ត្រូវបានតំណាងដោយលោក យ៉េត ចរិយា សហព្រះរាជអាជ្ញារង។

☒ លោក Robert Petit ត្រូវបានតំណាងដោយលោក Alex Bates, ជំនួយការជាន់ខ្ពស់របស់សហព្រះរាជអាជ្ញា។

លោកមេធាវី **កា សាវុត្ថ** និង Francois Roux សហមេធាវីរបស់ជនត្រូវចោទត្រូវបានកោះអញ្ជើញ នៅក្នុងដីកាកោះអញ្ជើញចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៨ និង មានលទ្ធភាពបានពិនិត្យសំណុំរឿងតាំងពីពេលនោះមក មានវត្តមានទាំងពីរនាក់។

**ការសួរចម្លើយ**

**សួរ-ឆ្លើយ:**

**សំនួររបស់លោកសហចៅក្រមស៊ើបអង្កេត** YBL: តើលោកនៅចាំបានទេថាកាលពីថ្ងៃទី៤ ទី៥ និង ទី៦ ខែឧសភា ឆ្នាំ១៩៩៩ លោកត្រូវបានសម្ភាសន៍ដោយអ្នកកាសែត និង ដោយអ្នកតំណាងរបស់UNHCHR (ឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស) ?

**កំណត់សម្គាល់របស់មេធាវី Francois Roux:** មុននឹងកូនក្តីរបស់ខ្ញុំឆ្លើយទៅនឹងសំនួរនេះ ខ្ញុំសុំឲ្យកត់ត្រានៅក្នុងកំណត់ហេតុនេះនូវការរក្សាសិទ្ធិមួយចំនួនទាក់ទងនឹងឯកសារទាំងនោះ។ ការរក្សាសិទ្ធិនេះ មាន២ប្រភេទ: ទី១ លោកឌុចមិនមែនត្រូវបានសម្ភាសន៍តែដោយអ្នកកាសែតនោះទេ ប៉ុន្តែ ដោយអ្នកតំណាងនៃអង្គការសហប្រជាជាតិផងដែរ ដែលអ្នកតំណាងនេះ គួរតែបានរំលឹកគាត់ឲ្យដឹងអំពីសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយ ប៉ុន្តែ គេមិនបានធ្វើវាទេ។ ទី២ វាមានភាពច្រឡំបល់ចូលគ្នាទាក់ទងនឹងការបកប្រែខុសគ្នាជាច្រើននៃការសម្ភាសន៍នេះដែលត្រូវបានដាក់នៅក្នុងសំណុំរឿង។ មេធាវីការពារក្តី សុំឲ្យផ្តល់កាសែតថតចម្លងមួយច្បាប់ដល់យើង។ ការរក្សាសិទ្ធិទាំងនេះត្រូវបានកត់ត្រារួចហើយ ដូច្នេះ កូនក្តីរបស់ខ្ញុំអាចឆ្លើយទៅនឹងសំនួរនេះបាន។

**សំនួរលោក ML:** តើលោកអាចបញ្ជាក់បានទេថាតើនៅក្នុងលក្ខខណ្ឌណាការសម្ភាសន៍នេះត្រូវបានធ្វើឡើង? តើនរណាខ្លះមានវត្តមាននាពេលនោះ តើធ្វើនៅទីកន្លែងណា ហើយ តើនៅថ្ងៃខែឆ្នាំណា?

**ឆ្លើយ:** កិច្ចសម្ភាសន៍នេះបានធ្វើឡើងពីថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩៩៩ ដល់ថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៩៩ (កាលបរិច្ឆេទថ្ងៃទី៤ ទី៥ និង ទី៦ ខែឧសភា ដែលមាននៅក្នុងឯកសារសំណុំរឿង គឺមិនត្រឹមត្រូវនោះទេ) នៅសណ្ឋាគារមនោរម្យ ក្រុងបាត់តំបង។ ខ្ញុំសុំបញ្ជាក់ថាខ្ញុំមិនចង់ឲ្យប្រើពាក្យសម្ភាសន៍ទេ ពីព្រោះខ្ញុំត្រូវបានសួរចម្លើយដោយអ្នកតំណាងរបស់UNHCR ដែលមានបញ្ជីនៃសំណួរសម្រាប់សួរខ្ញុំតែម្តង។ ពីដំបូងខ្ញុំបានបដិសេធមិនឆ្លើយ ប៉ុន្តែពួកគេបានប្រាប់ខ្ញុំថាពួកគេមានអណត្តិពីអង្គការសហប្រជាជាតិ ដូច្នេះ ពួកគេមានសិទ្ធិសួរសំនួរខ្ញុំ។ ពួកគេចង់ឲ្យមានការថតសម្លេង និងរូបភាព ប៉ុន្តែ ខ្ញុំបានបដិសេធមិនឲ្យថតជាវីដេអូទេ។ អ្នកដែលមានវត្តមាន មានដូចតទៅ: ទី១ Christophe Peschoux ជាអនុរបស់ Thomas Hammaberg ដែលជាអ្នកតំណាងរបស់ UNHCR ទី២ Ruth Hugo ទទួលបន្ទុក UNHCR នៅបាត់តំបង ទី៣ ហេង ហាំខេង ជាអ្នកបកប្រែ ទី៤ អ្នកកាសែត Nate Thayer ទី៥ លោកឪពុក Bernard ជាបុព្វជិតសាសនាកាតូលិកដែលមានវត្តមានដើម្បីជួយខ្ញុំផ្នែកចិត្តសាស្ត្រ។ អ្នកដែលសួរសំនួរមានតែមួយនាក់ទេ គឺលោក Christophe Peschoux។

**សំនួរលោកML:** តើលោកមានបានជួបអ្នកកាសែត Nate Thayer និង Nic Dunlop ដាច់ដោយឡែកពីគ្នាឬទេ?

**ឆ្លើយ:** តាមពិតទៅខ្ញុំបានជួបអ្នកកាសែតទាំងនេះ ពីមុនមក ក្នុងរយៈពេលខ្លីបំផុត។ ជាដំបូង NIC Dunlop បានមកជួបខ្ញុំ រវាងថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៩ នៅភូមិអូរទទឹម ឃុំតាសាញ ស្រុកសំឡូត។ គាត់ បានថតរូបខ្ញុំ បន្ទាប់មកគាត់បានត្រឡប់មកជួបខ្ញុំម្តងទៀត នា១៥ថ្ងៃក្រោយមក។ គាត់បានសួរអ្នកភូមិទាក់ទងនឹងរឿងខ្ញុំ។ លោកចៅក្រម បានសួរខ្ញុំថាតើខ្ញុំបានអានសៀវភៅ Nic Dunlop ដែលមានចំណងជើងថា The Lost Executioner។ តាមពិតទៅ ខ្ញុំបានអានវារួចហើយ។ ខ្ញុំនឹងផ្តល់ឲ្យលោកចៅក្រមនូវការកត់សម្គាល់លាយលក្ខណ៍អក្សររបស់ខ្ញុំអំពីរបៀបដែលអ្នកកាសែតនេះបានពិពណ៌នាអំពីជំនួបរវាងខ្ញុំនឹងគាត់។ ខ្ញុំសុំបញ្ជាក់ថា ខ្ញុំបានណែនាំខ្លួនខ្ញុំទៅលោក NIC Dunlop ក្រោមឈ្មោះ ហង់ ពិន (ជាឈ្មោះហៅក្រៅ ជាផ្លូវការ ដែលខ្ញុំប្រើពេលខ្ញុំត្រឡប់ពីប្រទេសចិននៅខែកក្កដា ១៩៨៨) ពីព្រោះ ខ្ញុំចង់លាក់អត្តសញ្ញាណរបស់ខ្ញុំចំពោះអ្នកដែលមកពីខាងក្រៅ។ ប៉ុន្តែ ខ្ញុំសុំបញ្ជាក់ថាចាប់ពីឆ្នាំ ១៩៨០ មក អ្នកនៅសំឡូតទាំងអស់ស្គាល់ខ្ញុំក្រោមឈ្មោះ ឌុច រួមទាំងក្មេងៗផងដែរ។

**សំនួរលោក ML:** តើលោកមិនដែលជួបNic Dunlop និង Nate Thayer រួមគ្នាទេឬ?

**ឆ្លើយ:** ខ្ញុំចាំមិនច្បាស់ទេ។ អ្វីដែលខ្ញុំដឹងគឺ ការជួបមួយដងៗ មិនលើសពី២០នាទីទេ។ Nic Dunlop បានថតតែរូបទេ។ ចំណែកឯ Nate Thayer វិញ គាត់បានសួរសំនួរ តិចតួចទេនាពេលជួបលើកទីមួយ ប៉ុន្តែ បានសួរច្រើន នាពេលជួបលើកទី២នៅផ្ទះខ្ញុំនៅសំឡូត។ គាត់បានមកជាមួយ Christophe Peschoux គឺប្រហែលជា៤ថ្ងៃមុនការជួបរបស់យើងនៅសណ្ឋាគារនៅបាត់តំបង។ នាពេលជួបសម្ភាសន៍នោះ Christophe Peschoux មិនមានបញ្ជីនៃសំនួរនោះទេ

ហើយ កិច្ចសម្ភាសន៍នោះ មិនត្រូវបានថតយកសម្លេងទេ តាមដែលខ្ញុំដឹង។ Ruth Hugo ដែលមាន វត្តមាន នាពេលនោះដែរនៅសំឡូត បានណាត់ជួបខ្ញុំនៅការិយាល័យរបស់គាត់នៅបាត់ដំបង បន្ទាប់មកយើង បានចេញដំណើរទាំងអស់គ្នាទៅសណ្ឋាគារ។

**សំនួរលោក** ML: តើលោកអាចពន្យល់យើងអំពីលក្ខខណ្ឌនៃការចាប់ខ្លួនលោកបានទេ ហើយ តើចន្លោះពេលដែលលោកត្រូវបានគេបង្ហាញមុខ និង ការចាប់ខ្លួនលោក តើលោកមានបានព្យាយាមទាក់ទងនរណាម្នាក់ដែលអាចជួយលោកដែរឬទេ?

**ឆ្លើយ:** ខ្ញុំមិនបានទាក់ទងនរណាម្នាក់នោះទេ។ Thomas Hammaberg បានចេញសេចក្តីប្រកាសព័ត៌មានមួយដែលបង្ហាញថាខ្ញុំត្រូវបានរកឃើញហើយ ហើយ បានស្នើសុំទៅអាជ្ញាធររដ្ឋាភិបាលឱ្យធានាសន្តិសុខដល់ខ្ញុំ។ ថ្ងៃទី៦ ខែឧសភា ខ្ញុំត្រូវបានកោះហៅដោយនគរបាលខេត្តបាត់ដំបង (ខ្ញុំបានត្រឡប់ទៅសំឡូតវិញ មួយថ្ងៃមុន) ខ្ញុំបានចូលខ្លួនតាមការកោះហៅនោះ បន្ទាប់មកខ្ញុំត្រូវបានបញ្ជូនមកភ្នំពេញ។ ខ្ញុំសុំបញ្ជាក់ថា លោក Christophe Peschoux បានស្នើឱ្យខ្ញុំទៅជាប់គុកនៅប្រទេសបែលហ្ស៊ិក ហើយបានឱ្យខ្ញុំ ៥០ ដុល្លា ដើម្បីបង់ថ្លៃតាក់ស៊ីដើម្បីគេចខ្លួនទៅប្រទេសថៃ ដើម្បីឱ្យ Interpol រៀបចំបញ្ជូនខ្លួនខ្ញុំទៅប្រទេសបែលហ្ស៊ិក។ ខ្ញុំបានសួរគាត់ថាតើនរណាជាអ្នករ៉ាប់រងការសួរសុខទុក្ខនៃក្រុមគ្រួសារខ្ញុំ ប៉ុន្តែ ដោយសាខ្ញុំមិនទទួលបានចម្លើយ ខ្ញុំបានបដិសេធសំណើរបស់គាត់។

**សំនួរលោក** ML: ត្រឡប់មកលក្ខខណ្ឌនៃកិច្ចសម្ភាសន៍នាដើមខែឧសភា ១៩៩៩ នៅសណ្ឋាគារមនោរម្យខេត្តបាត់ដំបងវិញ ?

**ឆ្លើយ:** ខ្ញុំត្រូវបានសួររៀងរាល់ថ្ងៃ ពីម៉ោង ៧ ដល់ ម៉ោង១១ និង ពីម៉ោង ១៤ ដល់ ម៉ោង១៦ ចាប់ពីថ្ងៃទី៣០ ខែមេសា (ឬ ថ្ងៃទី១ ខែឧសភា?) រហូតដល់រសៀលថ្ងៃទី៣ ខែឧសភា។ កិច្ចសម្ភាសន៍នេះ ធ្វើឡើងនៅសណ្ឋាគារដែលគេបានជួលឱ្យខ្ញុំ ហើយ រាល់ចំណាយរបស់ខ្ញុំ ត្រូវបានបង់ដោយ Christophe Peschoux។ សំនួរសួរដោយលោក Christophe Peschoux ជាភាសាបារាំង ត្រូវបានបកប្រែជាភាសាខ្មែរដោយអ្នកបកប្រែ ហើយ ខ្ញុំបានឆ្លើយសំនួរជាភាសាខ្មែរ ហើយអ្នកបកប្រែ បានបកប្រែជាភាសាបារាំង។ លោកចៅក្រមបានសុំខ្ញុំឱ្យផ្តល់ឱ្យលោកចៅក្រមនូវកំនត់សម្គាល់ជាលាយលក្ខណ៍អក្សររបស់ខ្ញុំលើឯកសារទាំង២: T001 (ដែលមានចំណងជើងថា ៉ ការសួរចម្លើយកាំងហ្គេកអ៊ាវ ហៅឌុច ប្រធានមន្ទីរស២១ ថ្ងៃទី៤ ទី៥ ទី៦ ខែឧសភា ឆ្នាំ១៩៩៩ ៉ ) និង T07 គឺ D9 (ដែលមានចំណងជើងថា កិច្ចសម្ភាសន៍ជាមួយឌុច)។ ខ្ញុំនឹងផ្តល់ជូនលោកចៅក្រមនូវការកត់សម្គាល់ជាលាយលក្ខណ៍អក្សររបស់ខ្ញុំក្នុងពេលវេលាសមស្រប និង យ៉ាងយូរបំផុត នៅដើមខែកុម្ភៈ)។

**លោកចៅក្រម** YBL: វាជាការគ្រប់គ្រាន់ហើយដោយលោកគ្រាន់តែបញ្ជាក់ប្រាប់យើងអំពីចំនុចទាំងឡាយណាដែលលោកមិនយល់ស្របជាមួយអត្ថន័យនៃឯកសារនោះ។

**ឆ្លើយ:** ខ្ញុំយល់ច្បាស់ហើយអំពីចំនុចនេះ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boîte postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

**សំនួរលោក Alex Bates:** តើលោកបានឆ្លើយនឹងសំនួរដែលបានសួរមកលោក ដោយស្ម័គ្រចិត្តឬ? លោកបានលាក់អត្តសញ្ញាណរបស់លោកអស់២០ឆ្នាំមកហើយ តើមានមូលហេតុអ្វីដែលនាំឲ្យលោកឆ្លើយយ៉ាងលំអិតអំពីខ្លួនលោកនាពេលនោះ?

**ឆ្លើយ:** ទាក់ទងនឹងសំនួរទី១ ខ្ញុំមិនបានលាក់បាំងអ្វីទេជាមួយ Christophe Peschoux ហើយ ខ្ញុំបានឆ្លើយដោយស្ម័គ្រចិត្តទៅនឹងសំនួររបស់គាត់។ ទាក់ទងនឹងសំនួរទី២ ខ្ញុំសុំបញ្ជាក់ថា ខ្ញុំមិនដែលលាក់អត្តសញ្ញាណរបស់ខ្ញុំចំពោះប្រជាជនកម្ពុជាទេ ពួកគេដឹងថាខ្ញុំឈ្មោះ ឌុច ជាអតីតប្រធានស២១។ មុនការចាកចេញរបស់ខ្ញុំទៅកាន់ប្រទេសចិននៅឆ្នាំ ១៩៨៦ សុនសេនបានបញ្ជាខ្ញុំឲ្យប្តូរឈ្មោះ។ ដូច្នេះ ខ្ញុំបានប្រើឈ្មោះ ពិន ហើយ ខ្ញុំបានរក្សាទុកឈ្មោះនេះ ពេលខ្ញុំត្រឡប់មកពីប្រទេសចិន នៅឆ្នាំ ១៩៨៨ នៅពេលដែលខ្ញុំធ្វើការឲ្យសុនសេននៅ ក១៨។ ទាក់ទងនឹងហេតុផលដែលជំរុញឲ្យខ្ញុំនិយាយនៅឆ្នាំ ១៩៩៩ មានជាដំបូង គឺការណ៍ដែលគេមិនអាចមិននិយាយអំពីការពិតរបស់ស២១បាននោះទេ។ Nate Thayer បានពន្យល់ប្រាប់ខ្ញុំថាប៉ុលពត បដិសេធអត្ថិភាពនៃស២១ ហើយថាស២១ គឺជាការប្រឌិតរបស់យួន ហើយ ខ្ញុំគិតថា ខ្ញុំត្រូវតែពន្យល់។ លោកចៅក្រមបានសួរខ្ញុំប្រសិនបើការវិវត្តរបស់ខ្ញុំនាកំឡុងឆ្នាំ ១៩៩០ មានដើរតួរនាទីសំខាន់នៅក្នុងសេចក្តីសម្រេចចិត្តនិយាយរបស់ខ្ញុំ។ ខ្ញុំត្រូវការពេលវេលាដើម្បីឆ្លើយនឹងសំនួរនេះ ហើយដែលខ្ញុំនឹងនិយាយលំអិតជាមួយនឹងអ្នកជំនាញនៅក្នុងក្របខណ្ឌនៃកោសល្យវិច្ច័យចិត្តសាស្ត្រដែលលោកចៅក្រមនឹងរៀបចំឡើង។

**សំនួរលោក Alex Bates:** ជនត្រូវចោទ ទើបបាននិយាយថាសុនសេន នៅតែជាប្រធានរបស់គាត់នៅឆ្នាំ ១៩៨៦។ ប៉ុន្តែ គាត់បានពន្យល់ពីមុនថា គាត់ថ្កោលទោសអ្វីដែលបានកើតឡើងនៅស២១ ក្នុងនាមរបបកម្ពុជាប្រជាធិបតេយ្យ។ តើជនត្រូវចោទ អាចពន្យល់បានយ៉ាងដូចម្តេច អំពីការណ៍ដែលថា៧ឆ្នាំក្រោយមក គាត់នៅតែមិនបានផ្តាច់ទំនាក់ទំនងជាមួយមេដឹកនាំនៃរបបនោះ ជាអ្វីដែលបង្ហាញថាគាត់នៅតែសង្ឃឹមជានិច្ចអំពីជ័យជំនះរបស់ខ្មែរក្រហម?

**ឆ្លើយ:** ខ្ញុំសុំនិយាយថាខ្ញុំបានមកដល់សំឡូតនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៩ ហើយ ចាប់ពីពេលនោះមក ខ្ញុំ ហាក់ដូចជា “អ្នកទោសនៃរបបនោះ” អញ្ចឹង: គ្មាននរណាម្នាក់អាចចាកចេញពីសំឡូតបានទេ។ នៅឆ្នាំ១៩៨៥ ខ្ញុំទួលបន្ទុកបង្រៀន។ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨៦ ខ្ញុំបានទៅដល់មន្ទីរ ក១៨ ហើយ សុនសេនបានបញ្ជូនខ្ញុំទៅប្រទេសចិននៅចុងខែតុលាដើម្បីបង្រៀនភាសាខ្មែរដល់និស្សិតចិន។ ខ្ញុំបានទៅប្រទេសចិនសម្រាប់រយៈពេល២ឆ្នាំ ហើយ ខ្ញុំប្រើលិខិតឆ្លងដែនកម្ពុជាប្រជាធិបតេយ្យ។ ពេលដែលខ្ញុំនៅប្រទេសចិន ខ្ញុំស្ថិតនៅក្នុងប្រទេសកុម្មុយនិស្ត និង លើសពីនេះទៀតខ្ញុំស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ប្រពន្ធសុនសេន។ ដូច្នេះ មិនថានៅសំឡូតឬនៅប៉េកាំងទេ ខ្ញុំមិនគាំទ្ររបបខ្មែរក្រហមទេ ប៉ុន្តែ ខ្ញុំមិនអាចធ្វើផ្សេងពីនេះបានទេ។

**សំនួរលោក ML:** តើរហូតដល់ពេលណាដែលលោក “ជាអ្នកទោសនៃរបបនោះ” ?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

**ឆ្លើយ:** នៅឆ្នាំ១៩៨២ ប៉ុលពតបានដាក់ឱ្យខ្ញុំទទួលបន្ទុកផ្នែកសេដ្ឋកិច្ច នៅភូមិថ្កាំ ឃុំថ្កាំ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ដូច្នេះ ខ្ញុំដាច់ទំនាក់ទំនងជាមួយថ្នាក់លើរបស់ខ្ញុំ ប៉ុន្តែ ខ្ញុំស្ថិតនៅក្រោមការតាមដានរបស់ឈ្លបជានិច្ច។ តាមពិតទៅ ការដាច់ទំនាក់ទំនងមានបន្តិចម្តងៗ ទាហានខ្មែរក្រហមបានបែកជួរបន្តិចម្តងៗនៅក្នុងការបន្តសង្គ្រាមនោះ។ ខ្ញុំបានក្លាយជាគ្រូបង្រៀន ហើយ ខ្ញុំបានរកស៊ីទិញលក់ស្រូវ និងចិញ្ចឹមជ្រូក។ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៨៥ នៅថ្កាំ ខ្ញុំត្រូវបានចោរប្លន់ ហើយប្រពន្ធខ្ញុំត្រូវសម្លាប់។ ពីរបីខែក្រោយមក ប្អូនស្រីខ្ញុំ បានមករកខ្ញុំ ហើយ ខ្ញុំបានទៅរស់នៅសំឡូត ប្រហែលជានៅពេលដែលមាស មុត បានជម្លៀសប្រជាជននៅឃុំនោះ ហើយបញ្ជាឱ្យធ្វើការចាប់ផ្តើមវាយលុកប្រឆាំងនឹងរដ្ឋាភិបាលវិញ។ ខ្ញុំបានទៅថៃជាមួយប្រជាជននៅសំឡូត។ សមាគម ARC ទទួលបន្ទុកជួយជនភៀសខ្លួន ហើយ ខ្ញុំបានចាប់ផ្តើមធ្វើការឱ្យសមាគមនោះ នៅឆ្នាំ ១៩៨៧។

**ផ្អាកការធ្វើកំណត់ហេតុនៃការសួរចម្លើយ នៅវេលាម៉ោងដប់ពីរនិងដប់ប្រាំនាទីគត់ ។**

**នៅវេលាម៉ោងដប់បួននិងដប់នាទីល្ងាចនៃថ្ងៃដដែល យើងចាប់ផ្តើមបន្តការសួរចម្លើយតទៅទៀត។**

**សំនួរលោក YBL:** តើនៅស២១ មានបទបញ្ជាផ្ទៃក្នុងទាក់ទិននឹងវិធីនៃការសួរចម្លើយដែរឬទេ? បើមាន តើមានពីពេលណាមក ហើយ នរណាជាអ្នកបង្កើតវា?

**ឆ្លើយ:** បទបញ្ជា គឺចេញមកពីខ្ញុំ ខ្ញុំបានពន្យល់បទបញ្ជានេះទៅអ្នកសួរចម្លើយនាពេលនៃការបណ្តុះបណ្តាល។ ជាពិសេស ទម្រង់៤ នៃការធ្វើទារុណកម្ម ត្រូវបានអនុញ្ញាត (ការវាយ ការឆក់ខ្សែភ្លើង ការយកថង់ច្រកក្បាល និងការដាក់ទឹកចូលច្រមុះ) និង មានការបញ្ជាក់ថាប្រសិនបើអ្នកសួរចម្លើយណាម្នាក់ធ្វើឱ្យជនជាប់ឃុំស្លាប់ដាច់ចម្លើយ អ្នកសួរចម្លើយនោះជាអ្នកទទួលខុសត្រូវ។

**សំនួរលោក YBL:** ដូច្នេះ មិនមានបទបញ្ជាលាយលក្ខណ៍អក្សរទេមែនទេ?

**ឆ្លើយ:** មិនមានទេ។ លោកចៅក្រមបានសួរខ្ញុំថាតើបទបញ្ជាទាំងនោះ ត្រូវបានសរសេរនៅលើជញ្ជាំង ជាអាទិ៍ នៅលើក្តារខៀន។ ខ្លួនខ្ញុំផ្ទាល់ ខ្ញុំមិនដែលចូលក្នុងបន្ទប់សួរចម្លើយទេ ហើយ ខ្ញុំមិនដែលឃើញក្តារខៀនដែលមានសរសេរបទបញ្ជាទាំងនោះដោយដីសនោះទេ។ ខ្ញុំដឹងថាគេបានឃើញបទបញ្ជាទាំងនោះនៅស២១ ប៉ុន្តែ តាមយោបល់ខ្ញុំ វាត្រូវបានសរសេរបន្ថែមក្រោយថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ ដោយហេតុផលនយោបាយ។ ទោះយ៉ាងណាក៏ដោយ វាមិនមានមុនថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ទេ។

**សំនួរលោក YBL:** តើលោកអាចអះអាងយ៉ាងម៉េច ប្រសិនបើលោកមិនទាំងដែលបានចូលក្នុងបន្ទប់សួរចម្លើយផងនោះ?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

**ឆ្លើយៈ** ខ្ញុំសុំលើកឧទាហរណ៍មួយៈ ខ្ញុំដឹងថាគេបានរកឃើញការសរសេរមួយដែលមានបទបញ្ជាទាំង១០នៃការសួរចម្លើយ។ បទបញ្ជាទី៨ បញ្ជាក់ថា ‶ កុំយកលេសកម្ពុជាក្រោមបាំងមុខមាត់ក្បត់អាឯងឱ្យសោះ ‶ ប៉ុន្តែ នៅស២១ គេមិនដែលនិយាយអំពីកម្ពុជាក្រោមទាល់តែសោះ។ ដូច្នេះ ខ្ញុំ គិតថាវាជាការប្រឌិតតាមក្រោយប៉ុណ្ណោះ។

**សំនួរលោក ML:** វាហាក់ដូចជាចេញពីកំណត់សម្គាល់របស់អ្នកសួរចម្លើយស២១ ថា ចាប់ពីចុងឆ្នាំ១៩៧៨មក មាន ‶ មាគាថ្មី ‶ មួយដែលជា ‶ ការអត់ឱន ‶ ចំពោះជនកម្ពុជា ត្រូវបានយកទៅអនុវត្តនៅស២១ ‶ ហើយ ទារុណកម្មមិនត្រូវធ្វើលើអ្នកទោសខ្មែរទៀតទេ ប៉ុន្តែ ចំពោះតែអ្នកទោសវៀតណាម និងបរទេសតែប៉ុណ្ណោះ។ តើលោកអាចប្រាប់អ្វីខ្លះដល់យើងអំពីចំនុចនេះ?

**ឆ្លើយៈ** ខ្ញុំមិនមានផ្តល់ជាបញ្ជាពិសេសណាមួយអំពីទារុណកម្មនៅចុងឆ្នាំ១៩៧៨ទេ។ ខ្ញុំបានដឹងនាពេលក្រោយមកជាពិសេសតាមការអានសៀវភៅលោក Chandler ( ‶ ស២១ ឬ ឧក្រិដ្ឋកម្មដែលមិនទាន់បានផ្តន្ទាទោសរបស់ខ្មែរក្រហម ‶) ថាមានការរិតត្បិតការប្រើទារុណកម្មនាពេលនោះ។ ប៉ុន្តែ ខ្ញុំមិនបានបញ្ជាឱ្យធ្វើបែបនោះទេ។ ផ្ទុយទៅវិញ ខ្ញុំសង្កេតឃើញថានាសម័យនោះ បទបញ្ជាទាក់ទងនឹងទារុណកម្ម មិនត្រូវបានគោរពនោះទេៈ ទម្រង់ខ្លះនៃទារុណកម្មដែលមិនត្រូវបានអនុញ្ញាត ត្រូវបានអនុវត្ត ឧទាហរណ៍ការដកក្រចក ឬ ការបង្ខំឱ្យគោរពរូបផ្តែ ដែលមានក្បាលហូជីមិញ និង Lyndon Johnson។ នៅពេលដែលខ្ញុំ ដឹងរឿងនេះ (រូបភាពផ្តែ) ខ្ញុំមិនបានជំទាស់ ហើយក៏មិនបានលើកទឹកចិត្តដែរ ផ្ទុយទៅវិញ ចំពោះការដកក្រចក ខ្ញុំបានមានប្រតិកម្មដោយគំរាមថាខ្ញុំនឹងវាយការណ៍។ ម្យ៉ាងទៀត ខ្ញុំបានកត់សម្គាល់តាមរយៈការអានសៀវភៅលោក David Chandler គឺមានទម្រង់នៃទារុណកម្មមួយទៀត ឧទាហរណ៍ ការបង្ខំឱ្យផឹកទឹកលាមក ប៉ុន្តែ ខ្ញុំមិនបានដឹងរឿងនេះទេនាសម័យនោះ។

ទាក់ទងនឹងរឿងនេះដែរ ខ្ញុំអាចបន្ថែមថានៅចុងឆ្នាំ ១៩៧៧ ខ្ញុំបានសរសេរទៅលោកគ្រូសុនសេន ដើម្បីសុំជំនួយពីគាត់ ពីព្រោះ ចម្លើយសារភាពបានចោទប្រកាន់មនុស្សច្រើនពេក។ គាត់បានឆ្លើយមកខ្ញុំវិញថាអ្នកសួរចម្លើយ ត្រូវតែប្រយ័ត្នប្រយែង និង មិនត្រូវឱ្យមានចម្លើយសារភាពដែលឆ្លើយដាក់មនុស្សច្រើនពេកនោះទេ។ ខ្ញុំបានឱ្យគេវាយអង្គុលីលេខនូវការណែនាំរបស់គាត់ ហើយ ខ្ញុំបានចែកឱ្យអ្នកសួរចម្លើយម្នាក់ៗមួយច្បាប់។

**សំនួរលោក YBL:** តើពាក្យ **សំអាត ដោះស្រាយ** ឬ **កំទេច** មានន័យយ៉ាងដូចម្តេច? ពាក្យនេះប្រើនៅពេលណា នាសម័យកាលណា ចូរពន្យល់?

**ឆ្លើយៈ** ក្នុងក្របខ័ណ្ឌ ម១៣ និង ស២១ ពាក្យថា ដោះស្រាយ និង កំទេច មានន័យដូចគ្នា គឺយកជនរងគ្រោះទៅសម្លាប់ ប៉ុន្តែ ពាក្យ ដោះស្រាយ ត្រូវបានប្រើនាសម័យវ៉ននេត ហើយសម័យសុនសេន គេប្រើពាក្យ កំទេច។ ដោយឡែករបបលន់នុល ប្រើពាក្យ បោសសំអាត ប៉ុន្តែ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ ១៩៧៥ ជាពិសេសក្រោយពេលចាប់កុយធួន ខ្មែរក្រហមប្រើពាក្យ សំរិតសំរាំង។ ពាក្យនេះមានន័យថា ចាប់ជនរងគ្រោះជាឈុត (ចំនួនច្រើន)។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

**សំនួរលោក YBL:** ពាក្យដែលបានពន្យល់ខាងលើ សមាជិកគណៈមជ្ឈិមផ្សេងទៀត ប្រើដែរឬទេ? ពិសេសនៅក្នុងកំណត់ហេតុប្រជុំ មានប្រើពាក្យ ដោះស្រាយ តើពាក្យនេះមានន័យដូចការពន្យល់របស់លោកអម្បាញ់មិញដែរឬទេ?
**ឆ្លើយ:** នួនជានិងសុនសេន ប្រើពាក្យ កំទេច និង សំរិតសំរាំង។ ដោយឡែក វ៉នវ៉េត លែងជាមេរបស់ខ្ញុំទៀតហើយ។ ដោយឡែក ពាក្យ ដោះស្រាយ ដែលមាននៅក្នុងកំណត់ហេតុប្រជុំ គឺមានន័យដូចដែលខ្ញុំបានពន្យល់ខាងលើ។ ដូចមានពាក្យនៅក្នុងកំណត់ហេតុថា " ខ្មាំងផ្ទៃក្នុង ត្រូវបានដោះស្រាយ " មានន័យថា ខ្មាំងផ្ទៃក្នុងត្រូវបានអង្គអចិន្ត្រៃយ៍មជ្ឈិម សម្រេច និង ចាប់បញ្ជូនទៅស២១អស់ហើយ។

☒ ឯកសារច្បាប់ដើមនៃការថតរូបភាពនិងសម្លេង ត្រូវបានបិទស្លាកបោះត្រានៅចំពោះមុខជនត្រូវចោទនេះ និង មេធាវីរបស់ជននេះ និង ត្រូវបានចុះហត្ថលេខាដោយ យើង ក្រឡាបញ្ជី សហព្រះរាជអាជ្ញា ជនត្រូវចោទ និង មេធាវីរបស់ជននេះ។
☒ ឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាពនិងសម្លេង ត្រូវបានប្រគល់ឲ្យជនត្រូវចោទនេះ។

នៅវេលាម៉ោងដប់ប្រាំមួយ និងសាមសិបប្រាំនាទីល្ងាច យើងបានឲ្យក្រឡាបញ្ជីអានខ្លាំងៗនូវកំណត់ហេតុសួរចម្លើយរបស់ជនត្រូវចោទនេះ ទៅតាមអ្វីដែលបានកត់ត្រា។

☒ អានឲ្យស្តាប់ហើយ ជនត្រូវចោទ មិនមានជំទាស់អ្វីទេ ហើយ សុខចិត្តចុះហត្ថលេខា។

| ជនត្រូវចោទ | មេធាវីជនត្រូវចោទ | សហព្រះរាជអាជ្ញា | អ្នកបកប្រែ | ក្រឡាបញ្ជី | សហចៅក្រមស៊ើបអង្កេត |
|---|---|---|---|---|---|
| Charged person<br>Personne mise en examen | Lawyer of Charged person<br>Avocat de la Personne mise en examen | C0-Prosecutors<br>Co-procureurs | Interpreter<br>Interprète | Greffiers | Co-Investigating Judges<br>Co-juges d'instruction |